## ៦. ការពិនិត្យតាមដាននិងការពិនិត្យឡើងវិញលើការបំពេញការងារតាមវិស័យដោយផ្អែកលើលទ្ធផល

### ៦.១. ការកែលំអការពិនិត្យតាមដានតាមវិស័យផ្តោតលើលទ្ធផល

ដំណើរការពិនិត្យឡើងវិញ និងការពិនិត្យតាមដានផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៤-០៨ នឹងប្រើប្រាស់លទ្ធផល និងបទពិសោធន៍ជាមូលដ្ឋានពីការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០១-០៥ ដោយផ្តោតលើវត្ថុបំណង និងផលសំរេចនៃគោលនយោបាយដែលសំរេចបាន ធៀបនឹងការពិនិត្យតាមដានការរីកចំរើនលើសកម្មភាពមួយៗ និងធនធានសំរាប់ដំណើរការ ។ ដូច្នេះ ក្រសួងនឹងពង្រឹងសមត្ថភាពរបស់ខ្លួនក្នុងការកំណត់ចំណុចដៅកម្មវិធី និងផ្នែកមួយៗ ព្រមទាំងការពិនិត្យតាមដានទៀតផង ។

បទពិសោធន៍ដ៏សំខាន់នៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០១-០៥ គឺជាតំរូវការដើម្បីកំណត់អាទិភាព និងសំរួលម៉ាទ្រិកសកម្មភាពគោលនយោបាយ និងទិសដៅទាំងឡាយ ដើម្បីពង្រឹងចំណុចផ្តោតនៃរបៀបវារៈកំណែទំរង់។ បទពិសោធន៏មួយទៀតគឺមានការខ្វះខាតនូវការប៉ាន់ប្រមាណទុកជាមុននូវតំរូវការពេលវេលា សំរាប់ធ្វើសកម្មភាពគោលនយោបាយអោយទៅជាផលសំរេចគោលនយោបាយ ជាពិសេសលើមូលដ្ឋានពីមួយឆ្នាំទៅមួយឆ្នាំ។ ហេតុដូច្នេះការកំណត់ចំនុចដៅគោលនយោបាយ និងយុទ្ធសាស្ត្របានបង្ហាញពីស្មារតី និងមហិច្ឆិតានៃការកែទំរង់វិស័យអប់រំ ហើយនឹងត្រូវបានប្រើជាចំណុចគោលអំពីនិន្នាការក្នុងការបំពេញការងារវិស័យអប់រំ ។

ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០១-០៥ បានបញ្ចូលអាំងឌីកាទ័របំពេញការងារគោលនយោបាយមួយចំនួនដែលទាក់ទងនឹងវិធានការសមធម៌នៃការចូលរៀន គុណភាពនិងប្រសិទ្ធភាព ព្រមទាំងការអភិវឌ្ឍស្ថាប័ននិងការកសាងសមត្ថភាព ។ក្របខ័ណ្ឌពិនិត្យតាមដានការបំពេញការងារដែលបានកែលំអនៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៤-០៨ នឹងរួមបញ្ចូលនូវការកែប្រែមួយចំនួនដែលទាក់ទងនឹងការកែសំរួលយុទ្ធសាស្ត្ររួមមាន ១) អាំងឌីកាទ័រនៃការចូលរៀនក្នុងការបណ្តុះបណ្តាលជំនាញក្រៅប្រព័ន្ធ ២) អាំងឌីកាទ័រគុណភាពនិងប្រសិទ្ធភាពទាក់ទងនឹងកម្មវិធីចូលរៀនឡើងវិញ លក្ខណៈសម្បត្តិគ្រូបង្រៀន និងការពង្រាយគ្រូ ទិដ្ឋភាពការបំពេញការងាររបស់គ្រឹះស្ថានសិក្សា និងការសិក្សារបស់សិស្ស ៣) អាំងឌីកាទ័រអភិវឌ្ឍន៍ស្ថាប័នដែលទាក់ទងទៅនឹងកិច្ចបញ្ជិការគណនេយ្យ និងសវនកម្មអង្គភាពគ្រប់គ្រងថវិកា ព្រមទាំងការអភិវឌ្ឍមន្ត្រីអប់រំ ។ តារាងម៉ាទ្រិកគោលនយោបាយនៃការពិនិត្យ តាមដានដែលបានកែលំអរួច មានបង្ហាញនៅក្នុងតារាងទី ៧ ខាងក្រោមនេះ :

| វិសាលភាព | អាំងឌីកាទ័រសំខាន់ៗ |
|---|---|
| **១- ការចូលរៀនប្រកបដោយសមធម៌**<br>*(គិតទាំងយេនឌ័រ)* | ➢ និន្នាការនៃការចុះឈ្មោះចូលរៀនថ្នាក់ជាតិ ខេត្ត-ក្រុង និង ស្រុក-ខ័ណ្ឌ<br>➢ តុល្យភាពនៃការចុះឈ្មោះចូលរៀននៅទីក្រុង-ជនបទ និងយេនឌ័រ<br>➢ ចំនួនសិស្សដែលមកពីគ្រួសារក្រីក្របំផុត<br>➢ អត្រាឡើងថ្នាក់នៅកំរិតអប់រំមូលដ្ឋាន<br>➢ អត្រាត្រួតថ្នាក់នៅកំរិតអប់រំមូលដ្ឋាន<br>➢ អត្រាពិតចូលរៀនថ្មីនៅថ្នាក់ទី ១<br>➢ ទិដ្ឋភាពនៃការចុះឈ្មោះចូលរៀននៅឧត្តមសិក្សា និងការបណ្តុះបណ្តាលជំនាញ<br>➢ ការចុះឈ្មោះចូលរៀននៅសាលាបណ្តុះបណ្តាលគ្រូ |
| **២- គុណភាព និង ប្រសិទ្ធភាព** | ➢ ស្តង់ដាការសិក្សារបស់សិស្សនៅតាមថ្នាក់បឋមសិក្សាដែលបានជ្រើសរើស និងនៅថ្នាក់ទី ៩ និងទី១២<br>➢ លទ្ធភាពនៃសំភារៈសិក្សា និងគ្រូបង្រៀនដែលបានទទួលការបណ្តុះបណ្តាល<br>➢ ផលធៀបសិស្ស-គ្រូ<br>➢ ចំនួនសាលាបឋមសិក្សាមិនគ្រប់កំរិតថ្នាក់<br>➢ ការកំណត់ប៉ុស្តិ៍គ្រូបង្រៀន នៅតំបន់ដាច់ស្រយាលដែលជួបការលំបាក<br>➢ ចំនួនសិស្សដែលចូលរៀនឡើងវិញនៅថ្នាក់ទី ៣-៩<br>➢ គ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និងឯកជនដែលបានទទួលស្គាល់គុណភាព<br>➢ ចំនួនគ្រូបង្រៀនដែលមានកំរិតវប្បធម៌ថ្នាក់ ១០-១២ រឺខ្ពស់ជាងនេះ<br>➢ ភាពគ្រប់ដណ្តប់នៃសំភាររូបវ័ន្ត ផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យាពត៌មាន និងប្រាស្រ័យទាក់ទង |
| **៣- ការអភិវឌ្ឍន៍ និង ការកសាងសមត្ថភាពស្ថាប័ន** | ➢ បរិមាណ និងចំណែកថវិកាសំរាប់វិស័យអប់រំ<br>➢ បំណែងចែកថវិកាសំរាប់ការចំណាយលើការអប់រំមូលដ្ឋាន<br>➢ ទិដ្ឋភាពនៃការចំណាយ និងការបើកផ្តល់សាច់ប្រាក់ សំរាប់កម្មវិធីអាទិភាព<br>➢ ភាពគ្រប់ដណ្តប់នៃប្រព័ន្ធសវនកម្មផ្ទៃក្នុង<br>➢ ផលធៀបនៃការចំណាយ និងការបែងចែកថវិកាសំរាប់បៀវត្ស និងមិនមែនបៀវត្ស<br>➢ អត្រាពង្រាយបុគ្គលិកបង្រៀន និងបុគ្គលិកមិនបង្រៀន<br>➢ សមត្ថភាពប្រតិបត្តិការរបស់អង្គភាពគ្រប់គ្រងថវិកា<br>➢ លទ្ធផលបណ្តុះបណ្តាលរបស់ក្រសួងដែលបានពីកម្មវិធីទទួលស្គាល់គុណភាព |

ចំណុចដៅនៃការបំពេញការងារដែលជ្រើសរើស ត្រូវបានកំណត់នៅក្នុងតារាងម៉ាទ្រិកបំពេញការងារវិស័យអប់រំ ដែលបង្ហាញអំពីចំនុចគោលសំខាន់ៗ ក្នុងរយៈពេល ២០០៤-២០០៨ ( សូមមើលឧបសម្ព័ន្ធ ២ ) ។

ដំណើរការពិនិត្យតាមដានផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៤-២០០៨ ទទួលស្គាល់ថា មានការយឺតយ៉ាវក្នុងការអនុវត្តគោលនយោបាយ ដើម្បីកែលំអការបំពេញការងារតាមវិស័យ។ ការពិនិត្យតាមដានលើការបំពេញការងារប្រចាំឆ្នាំនិងតាមឆ្នាំបន្តបន្ទាប់រួមគ្នា ត្រូវបានកំណត់ធ្វើជាមូលដ្ឋានដើម្បីពិចារណាអំពីភាពយឺតយ៉ាវដែលអាចមាននៅក្នុងការអនុវត្តការងាររបស់វិស័យ។ ទាំងអស់នេះមានឆ្លុះបញ្ចាំងនៅក្នុងរបាយការណ៍បំពេញការងារតាមវិស័យ និងការពិនិត្យឡើងវិញពាក់កណ្តាលទស្សវត្សនៃផែនការអប់រំសំរាប់ទាំងអស់គ្នា ។

ដំណើរការពិនិត្យតាមដានផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៤-២០០៨ ត្រូវបានរៀបចំឡើងដើម្បីពង្រឹងទំនាក់ទំនងរវាងយុទ្ធសាស្ត្រអភិបាលកិច្ច និងគណនេយ្យភាព។ ដូច្នេះ ក្រសួងអប់រំ យុវជន និងកីឡានឹងផ្តល់របាយការណ៍កាន់តែជាក់លាក់មួយចំនួនទៅឱ្យអ្នកពាក់ព័ន្ធនានារួមមាន ក) របាយការណ៍ប្រចាំឆ្នាំជូនទៅរដ្ឋសភា ខ) របាយការណ៍បំពេញការងារអប់រំខេត្ត-ក្រុង គ) របាយការណ៍ស្តីពីការរីកចំរើននៃកម្មវិធីនីមួយៗ ឃ) របាយការណ៍សកម្មភាពរបស់នាយកដ្ឋាន ង) របាយការណ៍សិក្សាស្រាវជ្រាវពីប្រតិបត្តិការសំរាប់ប្រើប្រាស់ជាពិសេស ច) របាយការណ៍ប្រចាំឆ្នាំស្តីពីសវនកម្មផ្ទៃក្នុងទៅលើអង្គភាពគ្រប់គ្រងថវិកាសាលារៀន និងកម្មវិធីនានា។

ក្រសួងអប់រំ យុវជន និងកីឡាទទួលស្គាល់ថា បញ្ហាមួយនៃដំណើរការពិនិត្យតាមដានផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០១-០៥ នៅមានកំរិតមិនបានបង្ហាញភស្តុតាងគ្រប់គ្រាន់ ពីស្តង់ដាបំពេញការងាររបស់សាលារៀន និងការសិក្សារបស់សិស្សទេ។ ការដាក់អោយអនុវត្តប័ណ្ណរាយការណ៍របស់សាលារៀន និងការធ្វើតែសទូទាំងប្រទេស ចំពោះសិស្សនៅតាមកំរិតថ្នាក់ដែលបានជ្រើសរើស នឹងអាចដោះស្រាយបញ្ហានេះបាន។ ជាផ្នែកមួយនៃដំណើរការពិនិត្យឡើងវិញការបំពេញការងារវិស័យប្រចាំឆ្នាំ និងការងារកំពុងអនុវត្ត។ ក្រសួងអប់រំ យុវជន និងកីឡា នឹងផ្សព្វផ្សាយពតិមានជាសាធារណៈអំពីស្តង់ដាបំពេញការងាររបស់សាលារៀន និងការសិក្សារបស់សិស្ស ដើម្បីជាពតិមានដល់មាតាបិតាសិស្ស និងអ្នកធ្វើសេចក្តីសំរេចចិត្តដទៃទៀត ព្រមទាំងពង្រឹងការចូលរួមរបស់អ្នកពាក់ព័ន្ធ។

ការរៀបចំប្រព័ន្ធពិនិត្យតាមដានផែនការយុទ្ធសាស្ត្រវិស័យអប់រំ នឹងត្រូវផ្អែកលើអង្គភាពទទួលខុសត្រូវដូចខាង ក្រោម :

- *ការពិនិត្យតាមដានការបំពេញការងារវិស័យ* : ដោយអធិការដ្ឋានអប់រំ នាយកដ្ឋានផែនការ និងគណៈកម្មការជាតិអប់រំសំរាប់ទាំងអស់គ្នា។

- *ការពិនិត្យតាមដានលើផលប៉ះពាល់កម្មវិធី* : ដោយនាយកដ្ឋានផែនការ និងនាយកដ្ឋានជំនាញក្រោមឱវាទក្រសួង សំរាប់កម្មវិធីជាអាទិភាព និងកម្មវិធីដទៃទៀតរបស់ខ្លួន។
- *ការពិនិត្យតាមដានការរីកចំរើនរបស់កម្មវិធី* : ដោយមន្ទីរអប់រំ យុវជន និងកីឡា ខេត្ត-ក្រុង ជាពិសេសការិយាល័យផែនការ មន្ត្រីអធិការកិច្ច និងការិយាល័យហិរញ្ញវត្ថុសំរាប់ខេត្ត-ក្រុងរបស់ក្រសួង។
- *ការពិនិត្យតាមដានការអនុវត្ត* : ដោយមន្ត្រីថ្នាក់ស្រុក សមាគមន៏មាតាបិតាសិស្ស ក្រុមប្រឹក្សាឃុំ-សង្កាត់ និងគណៈកម្មការអប់រំសំរាប់ទាំងអស់គ្នាថ្នាក់ឃុំ-សង្កាត់។
- *សវនកម្មការបំពេញការងាររបស់ប្រព័ន្ធ* : ដោយអធិការដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អាជ្ញាធរជាតិសវនកម្មរបស់រដ្ឋាភិបាល និងរដ្ឋសភា។

បទពិសោធន៏ទទួលបានពីការពិនិត្យឡើងវិញកម្មវិធីគាំទ្រវិស័យអប់រំឆ្នាំ២០០៣ គឺសមត្ថភាពសំរាប់គ្រប់គ្រងពតិមាននៃការបំពេញការងារនៅមានកំរិត និងផ្តល់របាយការណ៏បំពេញការងារវិស័យមិនទាន់ពេល និងពុំបានពេញលេញ ជាពិសេសរបាយការណ៏ហិរញ្ញវត្ថុ ។ ដូចនេះ ជាអាទិភាពគឺត្រូវពង្រឹងប្រព័ន្ធពតិមានដែលផ្អែកលើបច្ចេកវិទ្យាពតិមាន ការប្រាស្រ័យទាក់ទងនៅគ្រប់កំរិត ជាពិសេសនៅស្រុក សាលារៀន តំបន់ដាច់ស្រយាល និងតំបន់ព្រំដែន ។

## ៦.២. ពង្រឹងដំណើរការពិនិត្យឡើងវិញរួមគ្នាការបំពេញការងារវិស័យអប់រំប្រចាំឆ្នាំ

នៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៤-០៨ ក្រសួងបញ្ជាក់ថែមទៀតពីការប្តេជ្ញាចិត្តដឹកនាំក្នុងការធ្វើរបាយការណ៏ និងការពិនិត្យតាមដានបំពេញការងារវិស័យរួមគ្នាប្រកបដោយតម្លាភាព តាមរយៈដំណើរការពិនិត្យឡើងវិញប្រចាំឆ្នាំកម្មវិធីគាំទ្រវិស័យអប់រំ។ ក្រសួងពិចារណាឃើញថា វត្ថុបំណងសំខាន់នៃដំណើរការពិនិត្យឡើងវិញកម្មវិធីគាំទ្រវិស័យអប់រំ គឺត្រូវស្រង់បទពិសោធន៏សំរាប់កែសំរួលគោលនយោបាយ និងយុទ្ធសាស្ត្រ និងផ្តល់វេទិកាសំរាប់សហការកសាងផែនការទៅមុខជាមួយអ្នកផ្តល់ជំនួយ អង្គការក្រៅរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធដទៃទៀត។ ដូច្នេះ ដំណើរការពិនិត្យឡើងវិញផែនការយុទ្ធសាស្ត្រវិស័យអប់រំ នឹងបន្តសំរបសំរួលគោលវិធីដែលអនុវត្តនៅក្នុងកំណែទំរង់កម្មវិធីវិកលដែលមានលក្ខណៈទន់ភ្លន់។ ក្រសួងផ្តល់តំលៃខ្ពស់ចំពោះឱកាសផ្សេងៗទៀត សំរាប់ពិគ្រោះយោបល់ និងពិនិត្យតាមដានជាមួយអ្នកពាក់ព័ន្ធ។ បន្ថែមលើការពិនិត្យឡើងវិញប្រចាំឆ្នាំវិស័យអប់រំ ក្រសួងបានប្តេជ្ញាផងដែរបន្តពង្រឹងយន្តការពិគ្រោះយោបល់ដែលកំពុងដំណើរការ ជាមួយអ្នកពាក់ព័ន្ធដទៃទៀតរួមមាន :

- ការពិគ្រោះយោបល់ប្រចាំខែជាមួយតំណាងអ្នកផ្តល់ជំនួយ និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីផ្តល់របាយការណ៏ ពិនិត្យតាមដានការរីកចំរើនលើបញ្ហាសំខាន់ៗ និងឯកភាពលើសកម្មភាពចាំបាច់នានា។

- ការចូលរួមយ៉ាងសកម្មជាមួយគណៈកម្មការជាន់ខ្ពស់សំរាប់ពិនិត្យតាមដានការរីកចំរើន តាមរយៈគណៈកម្មការបច្ចេកទេសរបស់គណៈកម្មការជាតិកែទំរង់រដ្ឋបាលសាធារណៈ និងក្រុមពិនិត្យតាមដានកម្មវិធីសកម្មភាពជាអាទិភាពរបស់ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។
- ពង្រឹងកិច្ចសំរបសំរួលជាមួយនឹងថ្នាក់ដឹកនាំរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយ តាមរយៈរបាយការណ៍រីកចំរើនរបស់វិស័យអប់រំ និងកិច្ចប្រជុំជាមួយក្រុមការងារវិស័យសង្គមកិច្ច និងក្រុមប្រឹក្សាជាតិសំរាប់អភិវឌ្ឍសង្គម ជាផ្នែកមួយនៃការរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ ។

ការរៀបចំការកសាងផែនការ និងការគ្រប់គ្រងសំរាប់ដំណើរការពិនិត្យឡើងវិញកម្មវិធីគាំទ្រវិស័យអប់រំនាពេលបច្ចុប្បន្ន នឹងត្រូវរក្សាទុកនៅដដែលដោយរួមទាំងការវាយតំលៃរួមគ្នាកម្មវិធីគាំទ្រវិស័យអប់រំរវាងក្រសួងអប់រំ យុវជន និងកីឡា អ្នកផ្តល់ជំនួយ អង្គការក្រៅរដ្ឋាភិបាល និងក្រុមសំរបសំរួលការពិនិត្យឡើងវិញដែលគាំទ្រដោយលេខាធិការដ្ឋានពិនិត្យឡើងវិញកម្មវិធីគាំទ្រវិស័យអប់រំ។ ការកសាងសមត្ថភាពបន្ថែមដល់នាយកដ្ឋានផែនការ និងនាយកដ្ឋានពត៌មាននិងកិច្ចការអាស៊ានគឺមានសារៈសំខាន់ជាទីបំផុត។ ការចាត់ចែងធ្វើរបាយការណ៍ ក៏ត្រូវបន្តអនុវត្តដូចជា : ១) របាយការណ៍បំពេញការងារប្រចាំឆ្នាំរបស់វិស័យអប់រំ ព្រមទាំងមានពត៌មានបន្ថែមដាក់នៅក្នុងស៊ីឌី ២) របាយការណ៍ប្រចាំឆ្នាំរបស់អ្នកផ្តល់ជំនួយ និង៣) របាយការណ៍ប្រចាំឆ្នាំរបស់អង្គការក្រៅរដ្ឋាភិបាល។

អគ្គលេខាធិការដ្ឋានអប់រំសំរាប់ទាំងអស់គ្នា ដែលបានបង្កើតឡើងនៅក្នុងឆ្នាំ២០០២ បានផ្តល់នូវឱកាសបន្ថែមទៀត ដើម្បីពង្រឹងដំណើរការពិនិត្យតាមដានការបំពេញការងារវិស័យអប់រំអោយបានកាន់តែខ្លាំងក្លាថែមទៀត។ អគ្គលេខាធិការដ្ឋានអប់រំសំរាប់ទាំងអស់គ្នាត្រូវធ្វើរបាយការណ៍ប្រចាំឆ្នាំ ស្តីពីការអប់រំសំរាប់ទាំងអស់គ្នាដោយផ្តោតលើការសំរបសំរួលអន្តរក្រសួងសំរាប់កម្មវិធីជាក់លាក់ដូចជាការអភិវឌ្ឍនិងគាំពារកុមារតូចនិងការងារសកម្មភាពរបស់គណៈកម្មការអប់រំសំរាប់ទាំងអស់គ្នានៅគ្រប់លំដាប់ថ្នាក់។ របាយការណ៍នេះត្រូវដាក់បញ្ចូលទៅក្នុងរបាយការណ៍ ស្តីពីការកសាងផែនការ និងអភិបាលកិច្ចអន្តរក្រសួងលើការបំពេញការងារវិស័យ។ ក្រសួងកំពុងតែពិនិត្យឡើងវិញលើវិសាលភាពនៃការកែតំរូវ កាលវិភាគរបស់សន្និបាតអប់រំថ្នាក់ជាតិ និងខេត្ត-ក្រុង ដើម្បីផ្សារភ្ជាប់ទៅនឹង ដំណើរការពិនិត្យឡើងវិញកម្មវិធីគាំទ្រវិស័យអប់រំ ។

បទពិសោធន៍ដែលទទួលបានពីការពិនិត្យឡើងវិញកម្មវិធីគាំទ្រវិស័យអប់រំ ក្នុងកំឡុងឆ្នាំ២០០១-២០០៣ បានផ្តល់ឱកាសដ៏ល្អដើម្បីពិភាក្សា និងចរចាជាមួយអ្នកផ្តល់ជំនួយនិងអង្គការក្រៅរដ្ឋាភិបាលស្តីពីកម្មវិធីជំនួយពីខាងក្រៅនាពេលបច្ចុប្បន្ន និងសំរាប់ពេលអនាគត។ ដូចនេះ ក្រសួងស្នើឱ្យប្រើប្រាស់ដំណើរការពិនិត្យឡើងវិញកម្មវិធីគាំទ្រវិស័យអប់រំ ដើម្បីសំរបសំរួល និងធ្វើអោយមានភាពរលូនដល់ការកសាងកម្មវិធី និងបេសកកម្មវាយ

តំលៃរបស់អ្នកផ្តល់ជំនួយ និងអង្គការក្រៅរដ្ឋាភិបាលនីមួយៗ។ ទាំងអស់នេះនឹងជួយកាត់បន្ថយ ចំណាយប្រតិបត្តិសំខាន់ៗនៃសកម្មភាពកសាងកម្មវិធីដោយឡែករបស់អ្នកផ្តល់ជំនួយ និងអង្គការក្រៅរដ្ឋាភិបាល នីមួយៗ។